# បដិមាតោចំនួន ២ រកឃើញនៅតំបន់ប្រាសាទបាកាណ

តោ គឺជាស្តេចចតុបាទដែលមានអនុភាពខ្លាំងពូកែរស់នៅខាងជើងភ្នំព្រះសុមេរុដែលជាកន្លែងអាទិទេពគង់នៅ។ នៅសម័យបុរាណ គេនិយមសាងបដិមាតោដាក់នៅខាងមុខប្រាសាទក្នុងតួនាទីជាឆ្មាំចាំការពារមិនឱ្យសភាវៈអាក្រក់ទាំងឡាយចូលទៅក្នុងសំណង់សាសនា។ ជាការចាប់អារម្មណ៍ ចាប់តាំងពីរវាងស.វ.ទី៨ ដល់ដើមស.វ.ទី១២ គេតែងសង្កេតឃើញថាសិល្បករបុរាណសាងបដិមាតោឈរដោយជើងបួន (ជើងមុខពីរ និងក្រោយពីរ) ដោយមានរូបរាងប្លែកគ្នាទៅតាមសម័យកាលនីមួយៗ។ ជាទូទៅ បដិមាតោដែលប្រណិតជាងគេ គេឃើញដំបូងនៅតំបន់ប្រាសាទសំបូរព្រៃគុក ដែលស្ថិតនៅតួប៉ម C1 ឬហៅថាប្រាសាទតោ ហើយបដិមាតោសរុបមានរហូតដល់ទៅ ៦។ បដិមាតោទាំងអស់ មានមាត់បើកធំ ធ្មេញសំប៉ែតធំ ភ្នែកបើកសំឡឹងមើលទៅមុខ រោមរួញសំពោងធំជាងដងខ្លួន កន្ទុយដាក់សន្ធឹងរហូតដល់ក្បាល ជើងទាំងបួននៅនឹងថ្កល់ឥតចលនា ក្បាលនិងដងខ្លួនមិនសមាមាត្រគ្នាទេ ពោល គឺក្បាលធំជាងដងខ្លួន តែសិល្បករឆ្លាក់យ៉ាងផ្ចិតផ្ចង់។ ទោះបីជាយ៉ាងណា អ្វីដែលគេយល់ថាកាន់តែពិសេស និងចម្លែកមិនដែលឃើញពីមុននោះ គឺមកដល់រវាងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨១ - ១២២០) គេបានប្រទះឃើញបដិមាតោចំនួន ២ ដែលឈរដោយជើងក្រោយតែពីរប៉ុណ្ណោះ។ តើបដិមាតោចំនួន២ ដែលឈរដោយជើងក្រោយទាំងពីរមានប្រវត្តិ និងលក្ខណបែបណាខ្លះ?

បដិមាតោទាំងពីរដែលយើងលើកមកសិក្សានៅពេលនេះ គឺរកឃើញនៅតំបន់ប្រាសាទបាកាណ ខេត្តព្រះវិហារ (ឯកសារជាច្រើនហៅទីនោះថា ព្រះខ័ន-កំពង់ស្វាយ) ហើយឯកសារភាគច្រើនមិនបានបញ្ជាក់អំពីទីតាំងជាក់លាក់ឡើយ។ ខ្លះទៀតក៏រៀបរាប់ថា បដិមាតោទាំងពីរនេះរកឃើញនៅប្រាសាទព្រះថ្កោល ដែលស្ថិតនៅកណ្តាលអាំងស្តុកទឹក (បដាក) ដ៏ធំមួយនៅតំបន់ប្រាសាទបាកាណតែម្តង។ សូមបញ្ជាក់ថា បដិមាតោទាំងពីរ គឺសុទ្ធសឹងតែឈរក្នុងទម្រង់ដូចគ្នាពោល គឺឈរដោយប្រើប្រាស់ជើងក្រោយទាំងពីរ រីឯជើងមុខលើកឡើងលើ។ ប៉ុន្តែ អ្វីដែលគួរកត់សម្គាល់នោះ នៅពេលលោក Louis Delaporte (មន្ត្រីផ្នែកស្រាវជ្រាវនិងប្រមូលសម្បត្តិបេតិកភណ្ឌខ្មែរយកទៅកាន់ប្រទេសបារាំង) បានមកដល់តំបន់ប្រាសាទបាកាណនៅក្នុងឆ្នាំ១៨៧៣-១៨៧៤ នោះ បដិមាតោទាំងពីរមានគំលាតពីគ្នាត្រឹមតែពីរឬបីជំហានប៉ុណ្ណោះ ឈរយ៉ាងសាហាវ ដោយលាតកណ្តាប់ដៃចេញក្រៅ ហើយបដិមាតោដែលឈររបៀបនេះ គឺលោកបានជួបជាលើកដំបូងហើយ។ លោកគិតថា ឥរិយាបថរបស់តោឈរដោយជើងក្រោយរបៀបនេះ ហាក់បង្ហាញអំពីការ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

គោរពដ៏ខ្ពង់ខ្ពស់ចំពោះបដិមាគោនេះ និងម្យ៉ាងទៀតបដិមាគោទាំងពីរគឺបាត់ជើងមុខចំនួនមួយដូចគ្នា ដែលការបាត់ជើងមុខមួយនេះ លោក Louis Delaporte រៀបរាប់ថា អ្នកស្រុកជំនាន់នោះក៏មានភ្ជាប់ជាមួយរឿងព្រេងទៀតផង ដែលរឿងព្រេងនោះជាប់ទាក់ទងនឹងពេលខ្មែរមានសង្គ្រាមជាមួយទ័ពសៀម ហើយទ័ពសៀមបានលួចជើងបដិមាគោដ៏សក្តិសិទ្ធិនេះទៅ។ ទោះបីនេះគ្រាន់តែជារឿងព្រេងដែលអ្នកស្រុកនិទានឡើងនៅពេលនោះក៏ដោយ តែឯកសារដ៏សំខាន់របស់លោក Louis Delaporte បានរំលេចឱ្យយើងដឹងច្បាស់ថា នៅចុងស.វ.ទី១៩ ក្នុងពេលដែលលោកមកដល់បដិមាគោទាំងពីរ គឺមានជើងមុខតែមួយប៉ុណ្ណោះ។

ទោះបីក្នុងពេលនោះ លោក Louis Delaporte បានដឹកជញ្ជូនវត្ថុបុរាណខ្មែរប្រណិតៗជាច្រើនទៅកាន់ប្រទេសបារាំងក៏ដោយ ក៏បដិមាគោទាំងពីរនេះ លោកពុំបានដឹកជញ្ជូនយកទៅទេ។ ពោល គឺទើបតែមកដល់ឆ្នាំ១៩៣១ បដិមាគោមួយ គេបានដឹកជញ្ជូនយកទៅរក្សាទុក និងដាក់តាំងបង្ហាញនៅសារមន្ទីរហ្គីមេ នាទីក្រុងប៉ារីស ប្រទេសបារាំង ហើយពេលនោះទៀតសោត គឺជាពេលដែលលោក Louis Delaporte បានស្លាប់រយៈពេល ៥ ឆ្នាំទៅហើយ (១៩២៥)។ ដោយសារតែជើងមុខរបស់បដិមាគោទាំងពីរ បាត់ផ្នែកខាងស្តាំដូចគ្នានោះ គឺវាងាយនឹងច្រឡំខ្លាំងណាស់ ប៉ុន្តែគេអាចសម្គាល់បាននៅជើងខាងក្រោយរបស់បដិមាគោទាំងពីរ។ បដិមាគោដែលគេដឹកយកទៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង គឺជើងក្រោយផ្នែកខាងស្តាំដាក់ទៅក្រោយ ហើយជើងក្រោយផ្នែកខាងឆ្វេងដាក់ទៅមុខ ពោល គឺផ្ទុយគ្នាជាមួយបដិមាគោមួយទៀតដែលដាក់ជើងក្រោយផ្នែកខាងស្តាំទៅមុខ និងផ្នែកខាងឆ្វេងទៅក្រោយ។ ទម្រង់មុខរបស់គោរកឃើញនៅតំបន់ប្រាសាទបាកាណ ដែលកំពុងស្ថិតនៅប្រទេសបារាំង គឺមានទឹកមុខកាចសាហាវ ច្រមុះធំ ភ្នែកលៀន ធ្មេញនិងចង្កូមធំៗ មាត់ធំ ពោល គឺមានទម្រង់មុខស្ទើរតែគ្នាជាមួយមុខព្រះកាល ឬរាហូដែលគេឆ្លាក់ឡើងនៅក្នុងរចនាបថបាយ័ន្តដែរ (ចុងស.វ.ទី១២ ដល់ដើមស.វ.ទី១៣)។ ក្រៅពីមុខរបស់គោ នៅលើដងខ្លួន និងផ្នែកសំខាន់សុទ្ធសឹងមានលម្អជាក្បាច់ផ្សេងៗដែលយើងធ្លាប់ឃើញនៅសម័យអង្គរ ហើយគោទប់លំនឹងដោយរាងអ៊ែនអននៅត្រង់ចង្កេះនិងត្រកាក។

ដោយឡែក បដិមាគោមួយទៀតដែលមានទម្រង់នៃការឈរដោយជើងក្រោយ និងរកឃើញនៅទីតាំងក្បែរគ្នាដែរ (តំបន់បាកាណ) គឺគេមិនបានយកទៅស្រុកបារាំងទាំងអស់នោះទេ ពោល ក្នុងឆ្នាំ១៩៣១ គេយកបដិមាគោចេញពីទីនោះចំនួន ១ ប៉ុណ្ណោះ។ ប៉ុន្តែ នៅវាងទសវត្សរ៍ ១៩៨០ គេបានដឹកជញ្ជូនយកបដិមាគោដែលនៅសល់មួយទៀត មកតម្កល់នៅគល់ស្ពានឥន្ទទូនាទីរួមខេត្តកំពង់ធំ។ បដិមាគោនោះ គឺមានរូបរាងស្ទើរដូចគ្នាបេះបិទជាមួយបដិមាគោដែល

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*រៀបរាប់ខាងលើ ពោល គឺខុសតែជើងក្រោយប៉ុណ្ណោះ។ អ្វីកាន់តែពិសេសទៀតនោះ បដិមាគោនោះ បានក្លាយទៅជាវត្ថុសក្ដិសិទ្ធិដែលអ្នកស្រុកកំពង់ធំតែងតែមកគោរពបូជា និងបន់ស្រន់ឥតឈប់ឈរ ហើយបទចម្រៀងជាច្រើនដែលកវីនិពន្ធល្បីៗតែងនៅជំនាន់នោះ គឺតែងរំលេចអំពីគោថ្មនេះនៅក្នុងបទចម្រៀងផងដែរ។ ក្នុងឆ្នាំ២០១២ ដោយហេតុថាបដិមាគោដែលតម្កល់នៅគល់ស្ពានកំពង់ធំ មានសភាពទ្រុឌទ្រោម និងជុំវិញខ្លួនពោរពេញទៅដោយទឹកថ្នាំពណ៌ និងស៊ីម៉ង់ត៍ច្រើនផង គេសម្រេចលើកយកបដិមាគោនេះ ទៅជួសជុលនៅរោងជាងថ្មនាសារមន្ទីរជាតិកម្ពុជា (រាជធានីភ្នំពេញ)។ ក្រោយមក នៅរវាងពាក់កណ្ដាលឆ្នាំ២០១៦ គេបានកសាងបដិមាគោថ្មីធ្វើអំពីថ្មមួយជំនួសវិញ ដោយសិល្បករយកគំរូតាមបដិមាគោមុនដដែល និងបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៦។ ទោះបីយ៉ាងណា ជំនឿដ៏មុតមាំរបស់អ្នកស្រុកកំពង់ធំទៅលើបដិមាគោចាស់ មិនបានងើបឡើងវិញចំពោះបដិមាគោដែលជំនួសថ្មីនោះឡើយ ពោល គឺសព្វថ្ងៃជំនឿទៅលើបដិមាគោនៅគល់ស្ពានកំពង់ធំបានសាបទៅហើយ។ ជាការកត់សម្គាល់បន្ទាប់ពីការជួសជុលបដិមាគោចប់សព្វគ្រប់ហើយ រាជរដ្ឋាភិបាលបានសម្រេចបញ្ជូនបដិមាគោដែលមានប្រភពមកពីតំបន់ប្រាសាទបាកាណ និងធ្លាប់តម្កល់នៅគល់ស្ពានកំពង់ធំ យកទៅរក្សាទុកនិងដាក់តាំងបង្ហាញនៅសារមន្ទីរធម្មជាតិសាកលសម្ដេចតេជោព្រះវិហារ ដ្បិតគេយល់ថាសារមន្ទីរនេះ គឺជាសមិទ្ធផលថ្មីមួយដែលកើតឡើងនៅក្នុងខេត្តព្រះវិហារ ហើយបដិមាគោនេះក៏ធ្លាប់មានអតីតស្ថិតនៅក្នុងខេត្តព្រះវិហារដូចគ្នា។*

*ជារួមមក បដិមាគោទាំងពីរដែលរកឃើញនៅតំបន់ប្រាសាទបាកាណដែលឈរដោយជើងក្រោយទាំងពីរ គឺអាចចាត់បញ្ចូលថាជាសិល្បៈដ៏កម្របំផុតនៅសម័យបុរាណខ្មែរ។ ដ្បិតបដិមាគោចាប់ពីស.វ.ទី៨ មកដល់ចុងសម័យអង្គរនៅស.វ.ទី១៤ គឺគេបានរកឃើញស្ទើររាប់មិនអស់ ប៉ុន្តែពុំមានបដិមាគោណាដែលឈរដោយជើងក្រោយ និងលើកជើងមុខដាក់ទៅលើបែបនេះឡើយ។ យើងពុំមានភស្តុតាងអ្វីមកអះអាងថា តើហេតុអ្វីបានជាសិល្បករបុរាណសាងបដិមាគោទាំងពីរនេះមកដូច្នេះឡើយ? ប៉ុន្តែ ទោះបីជាយ៉ាងណា ឆ្លងតាមការរៀបរាប់របស់លោក* Louis Delaporte *និងតាមការមើលឃើញជាក់ស្ដែងពីជំនឿរបស់អ្នកស្រុកកំពង់ធំ គឺទំនងសបញ្ជាក់ឱ្យឃើញថាអ្នកស្រុកមានជំនឿខ្លាំងទៅលើបដិមាគោទាំងពីរនេះ។ ជាការសោកស្ដាយ បដិមាគោទាំងពីរបានឃ្លាតចាកឆ្ងាយពីគ្នាប្រមាណ ៩៣ ឆ្នាំទៅហើយ ហើយក៏ភាគរយតិចតួចណាស់ដែលបដិមាគោទាំងពីរនេះអាចមកជួបជុំគ្នាបាន ប្រសិនបើយោងទៅលើ* ***អនុសញ្ញាស្ដីពីការហាមឃាត់និងទប់ស្កាត់ការនាំចូលដោយខុសច្បាប់*** *ឆ្នាំ១៩៧០ របស់អង្គការយូណេស្កូ។*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

# ឯកសារយោង

លាង ស៊ីណាំ. ២០០៧. *ចម្លាក់តោក្នុងសិល្បៈខ្មែរ,* សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី ១៥ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

Baptiste, P. & Zéphir, T. 2008. *L'Art Khmer dans les collections du musée Guimet,* Paris.

Boisselier, J. 1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris.

Coedès, G. 1910. 'Catalogue des pièces originales de sculpture khmere conserves au musée indochinois du Trocadéro et au musée Guimet', Extrait du *Bulletin de la Commission archéologique de l'Indochine,* Ernest Leroux Editeur et Imprimerie nationale, Paris.

Delaporte, L. 1880. *Voyage au Cambodge, L'architecture Khmer,* Librairie Ch. Delagrave, Paris.

Dupont, P. 1934, *Musée Guimet, catalogue des collections indochinoises,* Extrait du *Bulletin de la Commission archéologique de l'Indochine, années* 1931-1934, Imprimerie nationale et éditions Ernest Leroux, Paris.

Parmentier, H. 1939. *L'Art Khmer classique. Monuments du quadrant nord est* [un volume de texte et un volume de planches], EFEO, vol XXIX bis, Les éditions d'Art et d'Histoire, Paris.

Phillipe,J. 2014. 'Les missions de 1866, 1873 et 1881', *Angkor Naissance d'un Mythe Louis Delaporte et le Cambodge,* pp. 40-43. Paris.

Zéphir, T. 1997. *L'Empire des rois Khmers,* Gallimard (coll 'Découvertes"310) et Réunion des musées nationaux, Paris.

Zéphir, T. 2014. 'Louis Delaporte, une vie au service d'Angkor', *Angkor Naissance d'un Mythe Louis Delaporte et le Cambodge,* pp. 38-39. Paris.

## Abstract

Lion is a powerful and powerful animal who lives north of Mount Sumeru, where the deity resides. In ancient times, it was customary to build a lion statue in front of the temple as a guard to prevent evil spirits from entering religious buildings. It is definitely rare to see two lion statues built in the late 12th and early 13th centuries found in Bakan, standing with both hind legs. Today, a lion statue is on display at the National Museum of France, transported from its original location in 1931 by the French colonial authorities. Another lion statue is on display at the Thomacheat Samdech Techo Preah Vihear Museum, transported from its original location in the 1980s. The two lion statues can be considered as one of the rarest and most unique arts ever in ancient times and are likely to reflect the people's belief in these two lion statues.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ១៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ*
*(កំពុងរក្សាទុកនៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង មើលចំពីមុខ)*

*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*



រូបលេខ២៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ
(កំពុងរក្សាទុកនៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង មើលពីចំហៀង)

អត្ថបទដោយៈ ម៉ង់ វ៉ាលី



រូបលេខ៣៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ

(កំពុងរក្សាទុកនៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង មើលលម្អិតពីមុខចំ)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៤៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ
(កំពុងរក្សាទុកនៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង មើលលម្អិតពីចំហៀង)

អត្ថបទដោយៈ ម៉ង់ វ៉ាលី




រូបលេខ៥៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ (រូបថតចាស់ ទសវត្សរ៍ ១៩៣០, EFEO)
(កំពុងរក្សាទុកនៅសារមន្ទីរជម្មជាតិសាកលសម្តេចតេជោព្រះវិហារ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ២៦៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ (រូបថតចាស់ ទសវត្សរ៍ ១៩៣០, EFEO)
(កំពុងរក្សាទុកនៅសារមន្ទីរជម្មជាតិសាកលសម្ដេចតេជោព្រះវិហារ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ៧៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ (រូបថតចាស់ ទសវត្សរ៍ ១៩៣០, EFEO)

(កំពុងរក្សាទុកនៅសារមន្ទីរជម្មជាតិសាកលសម្តេចតេជោព្រះវិហារ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ២៨៖ បដិមាតោរកឃើញនៅតំបន់ប្រាសាទបាកាណ (រូបថតថ្មី ឆ្នាំ២០២១)*
*(កំពុងរក្សាទុកនៅសារមន្ទីរជម្មជាតិសាកលសម្តេចតេជោព្រះវិហារ)*

អត្ថបទដោយ៖ ម៉េង វ៉ាលី